# ប្រជុំរឿងព្រេងខ្មែរ
# ភាគទី៨



## រឿង អ្នកតាក្របាចក

បណ្ណាល័យ សភនវស

# ១៩- អ្នកតាក្រហមក

ប្រជុំរឿងព្រេងខ្មែរភាគ ៨ ពីទំព័រទី ១១៥ – ១២២

អ្នកតាក្រហមកបិតនៅភូមិមហារាជ សព្វថ្ងៃគេហៅថា ភូមិឈើទាល សង្កាត់បឹងត្រាញ់ ស្រុកសំរោង ខេត្រតាកែវ ។ អ្នកតានេះ មានខ្ទមធ្វើដោយឈើប្រក់ស្លឹកជញ្ជាំងក្តារ ។ អ្នកស្រុកទើបនឹងសង់អាស្រមថ្មីមួយទៀតដោយស៊ីម៉ងត៍ នៅទន្ទឹមគ្នានឹងខ្ទមចាស់ពីមុន ។ នៅពីខាងក្រោយអាស្រមមានដំបូក ហើយមានដើមឈើដុះស៊ុមទ្រុម តាំងនៅលើដីទួលមួយខ្ពស់ ដែលអ្នកស្រុកនេះនិយមហៅថា "លោកតាភូមិ" ។ លោកតាម្នាក់និយាយថា: អ្នកតានេះមិនដឹងជាមានពីកាលណាទេ គាត់កើតឡើងដឹងក្តីកាលណា ក៏ឃើញអ្នកតានេះតែម្តង ប្រហែលជាកើតមានពីត្រឹមសម័យដែលមនុស្ស មកតាំងនៅលើភូមិមហារាជនេះ ។ អ្នកតានេះ មានឥទ្ធិពលលើអ្នកស្រុកភូមិនេះណាស់ ចេះជួយថែរក្សាសេចក្តីសុខ និងជួយរកយុត្តិធម៌ឲ្យអ្នកស្រុក-ភូមិទៀតផង ។ សម័យដើម កាលបើមានរឿងរ៉ាវផ្សេងៗ កើតឡើងរវាងអ្នកភូមិ ឬមានការឈ្លោះទាស់ទែងគ្នាជាដើម គេតែងទៅប្តឹង-ស្បថចំពោះមុខអ្នកតានោះ រាប់រៀបតាមដំណើររឿងរៀងៗខ្លួន ហើយមានសូត្រពាក្យស្បថប្រាំធានទៀតផង គូវិវាទទាំងពីរក៏សុខចិត្តរៀងៗខ្លួនជាការស្រេច មិនបាច់ប្តឹងផ្តល់ដល់រដ្ឋការមុខក្រសួងទៀតទេ ។ ពាក្យសម្បថនេះ ឃើញថាស័ក្តិសិទ្ធិមែន បើអ្នកណាប្រព្រឹត្តពុំសុចរិតទៀងត្រង់ទេ អ្នកនោះមុខជាអន្តរាយរហូតដល់ស្លាប់យ៉ាងទាន់ហាន់ក៏សឹងមាន ។

ម្យ៉ាងទៀត អ្នកតានេះស្អប់ណាស់ មនុស្សណាពាក់មួក ជិះដំរី និងស្ត្រីមានផ្ទៃពោះ ដើរកាត់មុខមិនបានទេ នឹងបណ្តាលឲ្យរលូតកូន បើអ្នកមានបុណ្យស័ក្តិនឹងធ្លាក់បុណ្យស័ក្តិ ។ អ្នកស្រុកខ្លាចហើយមិនហ៊ានប្រព្រឹត្តបំពានចំពោះរឿងនេះទេ ។

អ្នកស្រុកដំណាលតៗមកថា ប្រមាណជា ៤០ ឬ ៥០ ឆ្នាំកន្លងទៅហើយ មានតាចាស់ម្នាក់ឈ្មោះង៉ែត ប្រពន្ធឈ្មោះលឿង ផ្ទះគាត់នៅចម្ងាយប្រមាណ ៤០០ម ពីទិសអាគ្នេយ៍នៃអាស្រមអ្នកតានោះ ។ តា ង៉ែត ជាអ្នករកស៊ីធ្វើទឹកត្នោត គាត់បានធ្វើទឹកត្នោតមួយដើមក្បែរខ្ទមអ្នកតានេះឯង ។ ពេលដែលឡើងគាបត្នោតនោះម្តងៗ តាង៉ែតចេះតែជ្រលួសមាត់ក ដោយគាបទៅវាបាក់ ឬក្រឡាច់ផ្កាត្នោតពីឃ្នាប ។ អ្នកតានេះខឹង ក៏ច្រានតា ង៉ែត ទម្លាក់ពីចុងត្នោតមកដី ហើយទៅចូលរូបអ្នកស្រុកម្នាក់ ឲ្យនិយាយថា "លោកតាមិនឲ្យតា ង៉ែតធ្វើត្នោតទៀតទេ ឲ្យរកស៊ីអ្វីដទៃទៀតទៅ កុំដើរគាបផ្កាគេទៀត គេឈឺណាស់ ។ គ្រោះជាតាង៉ែត មិនស្លាប់ក្នុងពេលនោះដែរ ។ តែលុះគាត់បានស្រាកស្រាន្តជាចាកជំងឺ មានកម្លាំងស្រួលបួលឡើងវិញ គាត់ក៏ចាប់ធ្វើរបរត្នោតទៀត គាត់ធ្វើដើមដដែលហ្នឹង ។ ពេលនោះអ្នកតាក្រហមក (អ្នកតាភូមិ) លែងច្រានតា ង៉ែត ទម្លាក់ដូចមុនទៀតហើយ អ្នកតាខឹងខ្លាំងណាស់ ដោយប្រដៅតា ង៉ែត មិនស្តាប់ ក៏ចាប់តា ង៉ែត យកទៅដាក់ច្រវាក់ភ្ជាប់នឹងសសរខ្ទមអ្នកតា អស់មួយយប់មួយថ្ងៃ ។ ប្រពន្ធកូនបាត់តា ង៉ែត ដើររកមិនឃើញសោះ រកចុះរកឡើងក៏បានឃើញតា ង៉ែត នៅខ្ទមអ្នកតា ។ ពេលនោះតា ង៉ែត ឃើញប្រពន្ធដើរ

ចូលទៅ ស្រែកប្រាប់មកថា "អញទៅមិនរួចទេ អញជាប់ច្រវាក់ជើងហើយ!" ។ ឮដូច្នោះ ប្រពន្ធកូនក៏ខំទាញគាត់ចេញពីខ្ទមអ្នកតា តែគ្មានកម្រើកសោះ ទាញយ៉ាងណាក៏មិនរួច គេឃើញជើងគាត់ទាំងពីរព័ទ្ធជាប់នឹងសសរខ្ទម ហើយឮសូរច្រវាក់ច្រាវៗនៅក្បែរគាត់នោះដែរ ។ ប្រពន្ធកូនខំទាញទាល់ចំណេះ នៅតែមិនរួច ក៏តាំងបែរបន់ចុះញ៉ម សុំឲ្យអ្នកតាលែងតា ង៉ែត នោះមកវិញ អ្នកតាក៏លែងតា ង៉ែត ឲ្យមកជួបជុំប្រពន្ធកូនវិញដូចធម្មតា ។ តាំងពីពេលនោះមក អ្នកស្រុកភូមិក៏នាំគ្នាជឿស៊ប់ ចំពោះអ្នកតានោះឥតងាករេ គេតែងបន់គ្រប់ៗគ្នា ក្នុងពេលណាដែលមានទុក្ខព្រួយ ឬ បាត់របស់ទ្រព្យផ្សេងៗ ឬ ក៏ចង់បានជ័យជម្នះក្នុងការលេងល្បែងស៊ីសងជាដើម ។ គោលបំណងនៃការបន់នេះច្រើនតែបានសម្រេចដូចបំណងរៀងៗរហូតមក ។ ឯរបៀបតង្វាយគេច្រើនថ្វាយស្លាធមិដៃ2 ១គូ ស្លាធមិដូង ១គូ មាន់ស្ងោរ ១ មាន់រស់ ឬ មាន់ធ្នាក់ នំ ចេក ប្រាក់ ទង់ ទៅតាមការដែលគេបានបន់ ។

របៀបឡើងអ្នកតា

ពិធីឡើងអ្នកតាក្រហមក ឬអ្នកតាភូមិនេះ គេកំណត់ធ្វើនៅថ្ងៃ ១៣ កើត ខែពិសាខរៀងរាល់ឆ្នាំ ។ អ្នកស្រុកមហារាជ (ភូមិឈើទាល) រៀបចំធ្វើពិធីនេះរៀងរាល់ឆ្នាំ ឆ្នាំខ្លះគេធ្វើបង្ហារួច និមន្តព្រះសង្ឃចំរើនព្រះបរិត្តរួចទេសនា ។ ព្រឹកឡើងនិមន្តព្រះសង្ឃដារ ឆាន់ ដល់ពេលល្ងាច ទើបគេចាប់ធ្វើពិធីបញ្ជាន់រូប ។ ប៉ុន្តែមានឆ្នាំខ្លះ គេធ្វើបញ្ជាន់រូបតែម្តង មិនមាននិមន្តព្រះសង្ឃឆាន់ទេ ។ អ្នកតានោះ មានរូបសម្នឹងជាភេទប្រុសសម្រាប់ចូលមកនិយាយកិច្ចការប្រាប់កូនចៅ ។ តារូបសម្នឹងនោះមានអាយុប្រមាណ ៥០ឆ្នាំ គឺអ្នកតាក្រហមកចូលជាន់តែម្តង ឥតមានអ្នកណារើសទេ ។ ប៉ុន្តែតមកខាងក្រោយ រូបនោះក៏កាន់តែចាស់ ចូលជាន់លែងកើត អ្នកស្រុកក៏រើសរករូបថ្មីទៀត ដោយគេបួងសួងថា "បើលោកតាស្រឡាញ់អ្នកណា សូមឲ្យចូលរូបអ្នកនោះចុះ ព្រោះរូបមុនចាស់ណាស់ហើយ ។ គេបួងសួងរួចហើយ ក៏ចាប់លេងភ្លេងខ្មែរ ឲ្យអ្នកតារើសរូបចូលទៅ ។ សព្វថ្ងៃនេះ ចូលរូបតាម្នាក់ឈ្មោះ តា អន ដែលជារូបថ្មី អាយុ ៥០ ប្លាយដែរទើបនឹងចូលធ្វើសម្នឹងក្នុងឆ្នាំ១៩៦៦ មុននេះគាត់នៅភូមិខ្នាអុង សង្កាត់បឹងត្រាញ់ ស្រុកសំរោង តាកែវ។

អំពីគ្រឿងសំណែនសម្រាប់ឡើងអ្នកតា

នៅថ្ងៃមុន ១៣ កើតខែពិសាខអ្នកស្រុកពីរនាក់ដើររៃអង្គាសប្រាក់ពីអ្នកភូមិទាំងអស់គ្នា ដើម្បីយកទៅទិញប្រដាប់ប្រដា សម្រាប់រៀបចំពិធី ។ កាលទិញឥវ៉ាន់សព្វគ្រប់ហើយ គេក៏ចាប់ធ្វើស្លាធមិដៃ ១គូ ដាក់ក្នុងខ្ទមអ្នកតា ព្រមទាំងមានចេក នំ បង្អែម ចម្អាប ដាក់ថ្វាយក្នុងរោងនោះផង ។ ក្រៅពីនេះមានធ្វើសង្ឃឹកមួយទទឹង ០ម.៦០ បណ្តោយ ១ម.២០ ។ នៅក្នុងសង្ឃឹកនោះ គេដាក់ស្រូវ អង្ករ ពោត សណ្តែក ល្ង អំបិល ប្រហុក ប្រាក់កាស ដែលអ្នកស្រុកភូមិគេយកមកដាក់ ។ ស្រូវអង្ករ គេដេរស្បោងតូចៗច្រកគ្រប់ៗគ្នាយកមកដាក់ ក្នុងម្នាក់ៗមានស្រូវ ១បាវ អង្ករ ១បាវ ប្រាក់ ១រៀល បាយសម្លសម្រាប់ដាក់លើសង្ឃឹក និងបាយសម្លសម្រាប់ឲ្យពួកអ្នកភ្លេងបរិភោគ ។ គេធ្វើជ្រូក១ ដាក់លើស្តូក និងមាន់ស្ងោរ ១គូ បង្អែម ១គូ ចម្អាប ១គូគ្រប់មុខសុទ្ធតែមួយគូៗទាំងអស់ ។ ពៃមួយប្រវែង ១ហត្ថរាងចតុកោណកែងស្មើ ក្នុងពៃគេដាក់បាយ

សម្ល ចេក នំ គ្រប់មុខឥវ៉ាន់ដែលមាន ។ មានពែមួយទៀតរាងឆកោណ មាន ៦ ថ្នាក់3 មានទ្រង់ទ្រាយពែប្រហែលនឹងអាក់ព័ទ្ធសូត្រ ក្នុងពែនេះ គេគេដាក់បង្អែម-ចម្អាប ដូចពែរាងចតុកោណកែងស្មើនោះដែរ ។

នៅខាងមុខរោងអ្នកតា គេក្រាលកន្ទេល ហើយរៀបដាក់ប្រដាប់ប្រដាទាំងអស់ ឲ្យរូបអង្គុយលើកន្ទេលក្រហម ក្បែររបស់ទាំងអស់នេះ បែរមុខទៅទិសខាងកើត ។ នៅពីមុខរូបមានរងមួយ ហើយរងមានដន្លាប់ក្រមួន ១ ស្លាបៀក ៥ ម៉ាត់ បារី ៥ ទៀន ទៀនអុជហើយ ១គូ ម្លូ ៣សន្លឹក ស្លាមួយ ប្រាក់ ២០រៀល ដែលគេដាក់ឲ្យរូបបាំង4 ។ រូបអង្គុយបត់ជើងទទូរក្រមា ដៃទាំងពីរចាប់រង របៀបទ្រោមបន្តិច ។ ពីមុខរូបនោះ គេរៀបឆ្វេង-ស្តាំជាជួរ គឺ មាន់ ១គូ បង្អែម ចម្អាប ១គូ ជ្រូកដាក់កណ្តាលខាងមុខបង្អែម និងចម្អាបទៅទៀត ។ តទៅទៀត គេដាក់ពែសង្ឃឹក សង្ឃឹកគេដាក់មុខឲ្យឈមមករកមុខអ្នកតា និងក្រុមភ្លេង ១វង់ មានទ្រ ១ ប៉ីពក ១ អ្នកច្រៀងម្នាក់ ស្គរ ២ ។ ពេលបញ្ជាន់រូបលេងភ្លេងប្រគំ ។

ពេលភ្លេងកំពុងតែលេង រូបធ្វើទ្រឹង ហាក់ដូចជាចាំស្តាប់ភ្លេង និងចម្រៀង បើអ្នកចម្រៀងច្រៀងមិនត្រូវទេ រូបចាប់ច្រៀងខ្លួនម្តង ទើបអ្នកតាក្រហមកចូល ។ ពេលចូលរូបមុនដំបូង អ្នកតានិយាយជាភាសាលាវ រួចទើបនិយាយភាសាខ្មែរជាខាងក្រោយ ។ មានម្នាក់អ្នកសួរ និងថ្វាយតង្វាយ ដែលតាមទម្លាប់អ្នកស្រុកហៅថា "ជើងព្រះ" ។ ជើងព្រះនេះ ចេះនិយាយភាសាខ្មោច ដូចដូង គេថា "មហាលៃ" ចេក គេថា "ត្រសូល"5 ជាដើម ។ល។ អ្នកចាំសួរនោះ គេសួរពីសុខទុក្ខក្នុងស្រុកភូមិ នឹងសុំកុំឲ្យមានជំងឺអាសន្នរោគ អុត ព្រោះជំងឺពីរមុខនេះ អ្នកស្រុកខ្លាចណាស់ សុំឲ្យមានទឹកភ្លៀងបរិបូណ៌ សុំកុំឲ្យមានក្រាជង្កូវស៊ីស្រូវ កុំឲ្យស្រូវពាយជាដើម ។

បន្ទាប់មករូបអ្នកតាចូលនោះ ចាប់ឲ្យចំណីខ្មោចព្រាយ ពេលដែលឲ្យចំណីគេបង្វែរសង្ឃឹកនោះ ឲ្យបែរមុខចេញ រូបចូលនោះចាប់យកអង្ករមកផ្លុំ រួចបាចទៅលើពែនិងសង្ឃឹក រួចចាប់លាជមកបាចលើពែនិងសង្ឃឹកទៀត ហើយគេឲ្យជូនពែនិងសង្ឃឹកនោះទៅ ។ មុនពេលយកសង្ឃឹកនិងជូនពែនោះទៅនោះ គេត្រូវចាក់បាយចាក់សម្ល បង្អែម ចម្អាប ដាក់លើពែនិងសង្ឃឹក រួចនាំគ្នាសែងពែនិងសង្ឃឹកនោះចេញទៅ ។ ឯរូបនោះក្រោកឈរ ដៃកាន់ដំបង ឬ ដាវ គ្រវីលោតដើរតាមក្រោយអ្នកសែងសង្ឃឹកនោះទៅដែរ ។ អ្នកលេងភ្លេងបទស្តេចដើរ មនុស្សក៏ក្រោកដើរហែទៅទាំងអស់គ្នា បានចម្ងាយ ៥០ម. ឬ ១០០ម. រូបត្រឡប់មកវិញ អ្នកសែងសង្ឃឹក ភ្លេង និងអ្នកហែទាំងអស់ ចេះតែហែទៅមុខទៀត បានចម្ងាយប្រហែល ៥០០ម. ទើបដាក់សង្ឃឹកនិងពែចោល ភ្លេងក៏ឈប់លេង អ្នកហែត្រឡប់មកវិញ ។

ឯប្រដាប់ប្រដានៅលើសង្ឃឹកទាំងប៉ុន្មាន ត្រូវអ្នកសែងនោះចាត់ការគឺ មាន់ស្ងោរ ជ្រូក គេបេះតែស្លឹកត្រចៀកបន្តិច ក្បាលបន្តិច ជើង កន្ទុយ ដាក់លើសង្ឃឹកនោះទៅ សល់ប៉ុន្មាន គេនាំគ្នាចែកគ្នាបរិភោគ ។ ប៉ុន្តែបើស្រុកមានកើតជំងឺអាសន្នរោគ ឬ អុត ហើយបើមានធ្វើពិធីនេះ គេមិនដែលហ៊ានយករបស់អ្វីមកវិញទេ ទុកចោលនៅនោះហើយ សូម្បីតែសត្វតិរច្ឆានក៏មិនហ៊ានស៊ីផង ។ សម័យសព្វថ្ងៃនេះ ពេលរៀបឡើងអ្នកតាក្រហមក មិនមានដាក់ជ្រូកទាំងមូលដូចមុនទេ គេទិញតែក្បាល ជើង និងកន្ទុយជ្រូកមកជាការស្រេច